# តារាងស្តីពីព័ត៌មានរបស់គម្រោង

លេខPIP : 923

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

## ផ្នែក ក

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

១. ឈ្មោះគម្រោង : គម្រោងខ្សែច្រវាក់ផលិតកម្មប្រកបដោយភាតរះបរិស្ថាន

២. កាលបរិច្ឆេទគម្រោង

កាលបរិច្ឆេទចាប់ផ្តើមគម្រោង 01/10/18

កាលបរិច្ឆេទបញ្ចប់គម្រោង 31/03/26

៣. ចំណាយគម្រោងសរុប $141,041,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

RESPONSIBLE UNIT MAFF, MoRWAM and MRD

អង្គភាពទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធាន និងឧតុនិយម និងក្រសួងអភិវឌ្ឍន៍ជនបទ

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងវិនិយោគជាទុន

៧. ប្រភពហិរញ្ញប្បទាន៖ បញ្ចូលគ្នារវាងថវិការ និងឥណទានផ្សេងៗ

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្រ្តបញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី២- ការលើកស្ទួយសហគ្រាសធុនមីក្រូ តូច និងមធ្យម ធុរកិច្ចថ្មី សហគ្រិនភាព និងការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរះបរិស្ថាន(CFACV) ដែលបានស្នើឡើងនេះ ដើម្បីជួយគាំទ្រផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មរបស់រដ្ឋាភិបាលដោយលើកកម្ពស់ការប្រកួតប្រជែងនៃខ្សែច្រវ៉ាក់តម្លៃកសិពាណិជ្ជកម្មនៅខេត្តកំពង់ចាម និងត្បូងឃ្មុំតាមមហាដងទន្លេមេគង្គ នៃច្រករបៀងសេដ្ឋកិច្ចភាគខាងត្បូងរបស់អនុតំបន់ទន្លេមេគង្គ (GMS) និងនៅខេត្តកំពត និងតាកែវតាមបណ្តោយច្រករបៀងសេដ្ឋកិច្ចឆ្នេរប៉ែកខាងត្បូង។ គម្រោងនេះនឹងជួយលើកកម្ពស់ភាពធន់ទ្រាំនឹងអាកាសធាតុ ដោយគាំទ្រហេដ្ឋារចនាសម្ព័ន្ធកសិកម្មសំខាន់ៗ និងជំនួញលើផលិតកម្មដំណាំស្រូវ ពោត ដំឡូងមី និងស្វាយ។ គម្រោងនឹងជួយបង្កើនផលិតភាព និងពិពិធកម្មដំណាំ ការកែលម្អសមត្ថភាពឃ្លាំងស្តុក, ការកែច្នៃ និងការធ្វើតេស្តគុណភាព និងសុវត្ថិភាពផលិតផល ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ថាមពលព្រះអាទិត្យ និងជីវថាមពល។ គម្រោងនឹងជួយពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័នសម្រាប់វិស័យកសិកម្មវៃឆ្លាត (CSA) និងបង្កើតបរិយាកាសគោលនយោបាយមួយដែលអាចធ្វើទៅបានសម្រាប់អាជីវកម្មប្រកបដោយភាតរះបរិស្ថាន។ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទសហការជាមួយក្រសួងធនធានទឹក និងឧតុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរខេត្តទទួលខុសត្រូវទាំងស្រុងចំពោះការអនុវត្តគម្រោងទទួលហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានព្រមព្រៀងគ្នារួមគ្នារវាងអ្នកខ្ចី(រាជរដ្ឋាភិបាល) និងធនាគារអេភិវឌ្ឍន៍អាស៊ី ហើយអនុវត្តអោយស្របតាមគោលនយោបាយ និងនីតិវិធីរបស់រាជរដ្ឋាភិបាល និងធនាគារអេភិវឌ្ឍន៍អាស៊ី(ADB)។ គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរះបរិស្ថាន (CFACV) មានលេខសម្គាល់គម្រោង: 48409-002 ហើយប្រភពនៃការផ្តល់ប្រាក់កម្ចី និងជំនួយឥតសំណងមានលេខ: L3661; L8346; និង G0579។ គម្រោងខ្សែច្រវ៉ាក់ផលិតកម្មដោយភាតរះបរិស្ថាន "Climate-Friendly Agribusiness Value Chains Sector Project (CFAVC)" ដែលបានចរចាលើកិច្ចព្រមព្រៀងផ្តល់ហិរញ្ញប្បទាន កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៨ ព្រមទាំងបានចុះហត្ថលេខានៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៨ រវាងរាជរដ្ឋាភិបាលកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាស៊ី(ADB) ហើយបានចូលជាធរមាននៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៨. យោងតាមក្រុមបេសកម្ម ADB ឆ្នាំ២០២៣ ជាទូទៅក្នុងពេលជាមួយគ្នានេះដែរ ដូចដែលបានបង្ហាញកស្តុតាងបញ្ជាក់ច្បាស់លាស់ខាងលើទាក់ទងសំខាន់ Covid 19 និងការខកខានអស់រយៈពេលជិត ២ឆ្នាំក្នុងការអនុវត្តគម្រោងនេះ ដូច្នេះគម្រោងនេះបានទទួលការពន្យារយៈពេល ១៨ខែ បន្ថែមទៀត ដោយចាប់គិតពីថ្ងៃទី១ ខែតុលា ឆ្នាំ២០២៤ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦។

### ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ ? គាំទ្រ

ការសម្របសម្រួលគោលនយោបាយគាំទ្រ (ការបណ្តុះបណ្តាលជំនាញនិងធនធានមនុស្ស ការជំរុញវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ការកសាងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្ម និងវិធានការផ្ដែកហិរញ្ញប្បទាន)

### ១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ.)

កសិកម្ម និងការគ្រប់គ្រងដីធ្លី Research and Extension Services

### ១២. ទីតាំងអនុវត្តគម្រោង (ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង)

កំពត, តាកែវ, ត្បូងឃ្មុំ , កំពង់ចាម,

### ១៣. គោលបំណងរបស់គម្រោង (ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង)

គម្រោងមានគោលបំណងគាំទ្រដល់ការបង្កើនប្រាក់ចំណូលដល់ប្រជាជនតាមជនបទ និងជំរុញការប្រកួតប្រជែងនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥

### ១៤. ការពិពណ៌នាអំពីគម្រោង (ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង)

- Output 1: កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្មឲ្យមានភាពប្រសើរឡើង ហើយធននឹងអាកាសធាតុ ដែលជាស្ពានក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញការប្រកួតប្រជែងខ្សែច្រវ៉ាក់ផលិតកម្មស្រូវ ពោត ដំឡូងមី និងស្វាយ ក្នុងខេត្តគោលដៅទាំងបួនខាងលើ។ សមាសសភាគនេះជាប់ទាក់ទងនឹងការស្តារ ហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីបង្កើនផលិតកម្ម និងប្រសិទ្ធភាពធនធាន កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល ហើយនឹងការលើកកម្ពស់គុណភាព និងបណ្តាញខ្សែច្រវ៉ាក់តម្លៃ ក្នុងការកាត់បន្ថយក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) និងការបង្កើនភាពធនទៅនឹងអាកាសធាតុ។

- Output 2: ការជំរុញការអនុវត្តកសិកម្ម និងកសិ-ធុរៈកិច្ចមានលក្ខណៈស្របទៅនឹងអាកាសធាតុ

- Output 3: ការរៀបចំឲ្យមានបរិយាកាសល្អសម្រាប់ការវិនិយោគកសិ-ធុរៈកិច្ចប្រកបដោយភាតរៈបរិស្ថាន។ គម្រោងនឹងគាំទ្រក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាណិជ្ជកម្មក្នុងការបង្កើតបរិយាកាសគោលនយោបាយអនុគ្រោះសម្រាប់កសិ-ធុរៈកិច្ចក្នុងការបញ្ជ្រាបការចូលរួមរបស់វិស័យឯកជនតាមរយៈភាពជាដៃគូរវាងឯកជនជាមួយកសិកម្មតាមកិច្ចសន្យា។

១៥. យុត្តិកម្មលើគម្រោង (បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស)

កែលម្អហេដ្ឋារចនាសម្ព័ន្ធនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្មឲ្យមានភាពប្រសើរឡើង ហើយធននឹងអាកាសធាតុ ដែលជាស្ពានក្នុងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធ ដើម្បីជំរុញការប្រកួតប្រជែងខ្សែច្រវ៉ាក់ផលិតកម្មស្រូវ ពោត ដំឡូងមី និងស្វាយ ក្នុងខេត្តគោលដៅទាំងបួនខាងលើ។ សមាសសភាគនេះជាប់ទាក់ទងនឹងការស្តារ ហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធជនបទ ដើម្បីបង្កើនផលិតកម្ម និងប្រសិទ្ធភាពធនធាន កាត់បន្ថយការបាត់បង់ក្រោយពេលប្រមូលផល ហើយនឹងការលើកកម្ពស់គុណភាព និងបណ្តាញខ្សែច្រវ៉ាក់តម្លៃ ក្នុងការកាត់បន្ថយក្នុងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ (GHG) និងការបង្កើនភាពធនទៅនឹងអាកាសធាតុ។ គម្រោងនឹងបណ្តុះបណ្តាលកសិករយ៉ាងហោចណាស់ ៤០ ០០០នាក់ (១៦ ០០០នាក់ជាស្ត្រី) ស្តីពីកសិកម្មវៃឆ្លាតធននឹងអាកាសធាតុ។ មិនតែប៉ុណ្ណោះគម្រោងនឹងធ្វើបង្ហាញការព្រៀបដីដោយកម្មរស្មី ដើម្បីធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាពការប្រើប្រាស់ទឹក និងលើកកម្ពស់សមត្ថភាពក្រុមកសិករប្រើប្រាស់ទឹកក្នុងការប្រត្តិបត្តិ និងគ្រប់គ្រងប្រព័ន្ធជាវាសាស្ត្រ។ គម្រោងនឹងសាងសង់ និងធ្វើអោយប្រសើរឡើងនូវរោងជាងគ្រឿងយន្តកសិកម្ម ៤កន្លែង និងបំពាក់ និងបំពាក់សម្ភារបណ្តុះបណ្តាលកសិ-ធុរៈកិច្ច៤កន្លែង ដើម្បីបណ្តុះបណ្តាលសហគមន៍កសិករប្រើប្រាស់ទឹក កសិករជាស្ត្រី និងសមាជិកសហគមន៍ កសិកម្មក្នុងការគ្រប់គ្រង និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងយន្តកសិកម្ម។ គម្រោងនឹងគាំទ្រសហគមន៍កសិកម្មក្នុងការប្រកបអាជីវកម្មកសិ-ធុរៈកិច្ចប្រកបដោយនិរន្តរភាពដោយផ្សារភ្ជាប់ជា មួយវិស័យឯកជន និងដោយបង្កើតវេទិកាភាពជាដៃគូរវាងឯកជនដោយផ្តោតទៅលើជំណាំ។ គម្រោងនឹងបង្ហាញចំណេះដឹងនៃស្ថាប័នហិរញ្ញវត្ថុ ស្តីពីហិរញ្ញវត្ថុបៃតង និងការធ្វើសមាហរណកម្មវិនិច្ឆ័យជម្រុះហានិភ័យអាកាសធាតុ និងបរិស្ថានទៅក្នុងការអនុវត្តប្រព័ន្ធក្រេឌីត និងនីតិវិធីធ្វើរបាយការណ៍។ គម្រោងនឹងផ្តល់ព័ត៌មានអាកាសធាតុ ទីផ្សារ និងក្សេត្រសាស្ត្រ ដើម្បីបង្កើតបរិយាកាសមួយសម្រាប់ការគ្រប់គ្រងហានិភ័យអាកាសធាតុកាន់តែមានប្រសិទ្ធិភាព ដោយការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា។

១៦. ផលប្រយោជន៍របស់គម្រោង (រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង)

គម្រោងនឹងបណ្តុះបណ្តាលកសិករយ៉ាងហោចណាស់ ៤០ ០០០នាក់ (១៦ ០០០នាក់ជាស្ត្រី) ស្តីពីកសិកម្មវៃឆ្លាតធននឹងអាកាសធាតុ។ មិនតែប៉ុណ្ណោះគម្រោងនឹងធ្វើបង្ហាញការព្រៀបដីដោយកម្មរស្មី ដើម្បីធ្វើអោយប្រសើរឡើងនូវប្រសិទ្ធភាពការប្រើប្រាស់ទឹក និងលើកកម្ពស់សមត្ថភាពក្រុមកសិករប្រើប្រាស់ទឹកក្នុងការប្រត្តិបត្តិ និងគ្រប់គ្រងប្រព័ន្ធជាវាសាស្ត្រ។ គម្រោងនឹងសាងសង់ និងធ្វើអោយប្រសើរឡើងនូវរោងជាងគ្រឿងយន្តកសិកម្ម ៤កន្លែង និងបំពាក់ និងបំពាក់សម្ភារបណ្តុះបណ្តាលកសិ-ធុរៈកិច្ច៤កន្លែង ដើម្បីបណ្តុះបណ្តាលសហគមន៍កសិករប្រើប្រាស់ទឹក កសិករជាស្ត្រី និងសមាជិកសហគមន៍ កសិកម្មក្នុងការគ្រប់គ្រង និងថែទាំ ហេដ្ឋារចនាសម្ព័ន្ធ និងគ្រឿងយន្តកសិកម្ម។

១៧. ការសិក្សាសមិទ្ធិលទ្ធភាព

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | មាន |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | ត្រូវបានបញ្ចប់ |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** (ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ?)

**គម្រោងមានគោលបំណងគាំទ្រដល់ការបង្កើនប្រាក់ចំណូលដល់ប្រជាជនតាមជនបទ និងជំរុញការប្រកួតប្រជែងនៃខ្សែច្រវ៉ាក់ផលិតកម្មកសិកម្ម ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម ២០១៤-២០១៨ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥**

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការត្រៀម**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

**គម្រោងនឹងបណ្តុះបណ្តាលកសិករយ៉ាងហោចណាស់ ៤០ ០០០នាក់ (១៦ ០០០នាក់ជាស្ត្រី) ស្តីពីកសិកម្មវៃឆ្លាតធននឹងអាកាសធាតុ។**

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

**ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទសហការជាមួយក្រសួងធនធានទឹក និងឧត្តុនិយម ក្រសួងអភិវឌ្ឍន៍ជនបទ និងមន្ទីរខេត្តទទួលខុសត្រូវទាំងស្រុងចំពោះការអនុវត្តគម្រោងទទួលហិរញ្ញប្បទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលបានព្រមព្រៀងគ្នារួមគ្នារវាងអ្នកខ្ចី(រាជរដ្ឋាភិបាល) និងធនាគារអភិវឌ្ឍន៍អាស៊ី ហើយអនុវត្តអោយស្របតាមគោលនយោបាយ និងនីតិវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។**

២៣. [illegible] របស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាល ឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងបានចាប់ផ្តើមអនុវត្តសកម្មភាពតាំងពីឆ្នាំ២០១៩ រហូតមកដល់ពេលនេះ គម្រោងស្ថិតក្នុងស្ថានភាពអនុវត្តសកម្មភាពហើយនឹងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៥។ ដោយបញ្ហាផលប៉ះពាល់ Covid-19 គម្រោងបានទទួលបានការពន្យារពេល ១៨ខែ បន្ថែមទៀតតាមរយៈក្រុមបេសកម្មADB ក្នុងឆ្នាំ២០២១ (ពី ២២ ដល់ ២៩ វិច្ឆិកា ឆ្នាំ២០២១) ។ ដូច្នេះគម្រោងនឹងបន្តរហូតដល់បញ្ចប់គម្រោងរហូតដល់ថ្ងៃទី ៣១ ខែមីនា ឆ្នំ ២០២៦។ គិតត្រឹមឆ្នាំ២០២២ ថវិកាសរុបទាំងមូលនៃគម្រោង CFAVC មានចំនួន ១៤១,០៤០ លានដុល្លអោមេរិក ត្រូវបានបែងចែកនិងការទទួលខុសត្រូវដល់អង្គភាពគ្រប់គ្រងគម្រោង (PMU) នៃក្រសួងទាំងបី៖ (១. MAFF មានចំនួន ៥៦,៣៤ លានដុល្លអោមេរិក, ២. MoWRAM មានចំនួន ៤៤,២៤ លានដុល្លអោមេរិក និង ៣. MRD មានចំនួន ៣៦,៣៤ លានដុល្លអោមេរិក) ។ សម្រាប់ផែនការសកម្មភាពនិងថវិការឆ្នាំ២០២២ (AWPB FY2022) បានលើកសរុបសម្រាប់ក្រសួងទាំងបី មានចំនួន ៣៧,០៧ លានដុល្លអោមេរិក៖ (១. MAFF មានចំនួន ១៣,៥១ លានដុល្លអោមេរិក, ២. MoWRAM មានចំនួន ១៤,៧០ លានដុល្លអោមេរិក និង ៣. MRD មានចំនួន ៨,៨៤ លានដុល្លអោមេរិក) ។ សម្រាប់ផែនការសកម្មភាពនិងថវិការឆ្នាំ២០២៣ (AWPB FY23) បានលើកសរុបសម្រាប់ក្រសួងទាំងបី មានចំនួន ៤៣,៤៥ លានដុល្លអោមេរិក៖ (១. MAFF មានចំនួន ២៤,៤២ លានដុល្លអោមេរិក, ២. MoWRAM មានចំនួន ៩,៧១ លានដុល្លអោមេរិក និង ៣. MRD មានចំនួន ៩,៣២ លានដុល្លអោមេរិក) ។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោង CFACV បានគ្រោងចំណាយថវិកាវិនិយោគសរុបចំនួនប្រមាណ ១៤១,០៤ លានដុល្លអោមេរិច។
ក្នុងនោះមានឥណទានសម្បទានរបស់ (ADB Loan number: L3661): ៩០ លានដុល្លអោមេរិច
ឥណទានសម្បទានរបស់មូលនិធិអាកាសធាតុបៃតង (GCF Loan numbers: L8346): ១០លានដុល្លអោមេរិច
ហិរញ្ញប្បទានឥតសំណងរបស់ GCF (Grant Numbers: G0579): ៣០លានដុល្លអោមេរិច ថវិកាចូលរួមពីអ្នកទទួលផល (Beneficiaries): ៣,៦៦លានដុល្លអោមេរិច និងថវិការាជរដ្ឋាភិបាលកម្ពុជា ៧,៣៨លានដុល្លអោមេរិច

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លអោមេរិក)*

| ចំណាយវិនិយោគ | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 748.4 | 830.6 | 747.0 | 747.0 | 747.0 | 0.0 | 1,494.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 647.8 | 461.3 | 100.0 | 100.0 | 100.0 | 0.0 | 200.0 | 0.0 |
| សម្ភារៈនិងរដ្ឋបាល | 100.6 | 170.3 | 647.0 | 647.0 | 647.0 | 0.0 | 1,294.0 | 0.0 |
| ផ្សេងៗ | 0.0 | 199.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 23,668.6 | 21,689.3 | 33,163.0 | 28,963.0 | 17,663.0 | 0.0 | 46,626.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 9,665.6 | 8,734.0 | 9,500.0 | 9,500.0 | 9,500.0 | 0.0 | 19,000.0 | 0.0 |
| សេវាទីប្រឹក្សា | 4,002.1 | 7,617.3 | 4,000.0 | 4,000.0 | 3,000.0 | 0.0 | 7,000.0 | 0.0 |
| ទិញសម្ភារៈ | 3,388.8 | 196.4 | 3,000.0 | 3,000.0 | 2,000.0 | 0.0 | 5,000.0 | 0.0 |
| ការបណ្តុះបណ្តាល | 6,612.1 | 2,774.4 | 6,500.0 | 6,500.0 | 2,500.0 | 0.0 | 9,000.0 | 0.0 |
| ផ្សេងៗ | 0.0 | 2,367.2 | 10,163.0 | 5,963.0 | 663.0 | 0.0 | 6,626.0 | 0.0 |
| | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយសរុប | 24,417.0 | 22,519.9 | 33,910.0 | 29,710.0 | 18,410.0 | 0.0 | 48,120.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2023 | | 2024 | 2025 | 2026 | 2027 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2025-2027 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 44,554.7 | 22,320.9 | 47,647.4 | 695,218.0 | 29,795.4 | 0.0 | 725,013.4 | |
| | | | | | | | | |
| **ថវិកាជាតិ** | 668.8 | 683.3 | 15.0 | 300.0 | 370.0 | 0.0 | 670.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 668.8 | 683.3 | 15.0 | 300.0 | 370.0 | 0.0 | 670.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 23,875.8 | 21,836.6 | 45,637.4 | 29,410.0 | 18,040.0 | 0.0 | 47,450.0 | |
| | | | | | | | | |
| Asian Development Bank | 23,380.4 | 18,808.0 | 30,399.4 | 19,940.0 | 11,670.0 | 0.0 | 31,610.0 | |
| Global Environment Facility | 495.4 | 3,028.6 | 15,238.0 | 9,470.0 | 6,370.0 | 0.0 | 15,840.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 24,544.6 | 22,519.9 | 45,652.4 | 29,710.0 | 18,410.0 | 0.0 | 48,120.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | -127.601 | 0.0 | -11,742.4 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: